# សាលាមត្តេយ្យសក្យបុត្រអន្តរជាតិ

# Sakyaputra Kindergarten International School

## បទបញ្ជាផ្ទៃក្នុងសម្រាប់សិស្សានុសិស្ស

សិស្សសាលាមត្តេយ្យសក្យបុត្រអន្តរជាតិ ត្រូវគោរពវិន័យ ដើម្បីរក្សាបរិយាកាសសិក្សាល្អ និងគោរពតាមបទបញ្ជាផ្ទៃក្នុងនៃសាលាមត្តេយ្យសក្យបុត្រអន្តរជាតិ ដូចតទៅនេះ៖

១. ស្លៀកពាក់ឯកសណ្ឋាននិងតុបតែងខ្លួនឱ្យស្អាតបាតត្រឹមត្រូវ(គ្រឿងអលង្ការត្រូវបានហាមឃាត់ក្នុងសាលារៀន។

២. មិនត្រូវប្រើឬចែកចាយនូវកញ្ឆា ថ្នាំជក់ គ្រឿងស្រវឹង និងថ្នាំខុសច្បាប់ផ្សេងៗ ដែលទាក់ទងទៅនឹងសារធាតុញៀននៅក្នុងបរិវេណសាលា។

៤. មិនឱ្យកាន់អាវុធគ្រប់យ៉ាងក្នុងបរិវេណសាលាដូចជា៖ កាំភ្លើង កាំបិត កាំភ្លើងដំរ គ្រឿងផ្ទុះ ឬប្រដាប់ប្រើជាតិ គីមី និងវត្ថុផ្សេងៗដែលប្រើទៅនាំឱ្យគ្រោះថ្នាក់ដល់រូបកាយអ្នកដទៃ។

៦. មិនអនុញ្ញាតឱ្យជួញដូរវត្ថុគ្រប់បែបយ៉ាងនៅក្នុងបរិវេណសាលា។

៨. មិនឱ្យប្រមាថ ឬគំរាមកំហែងដើម្បីប្រព្រឹត្ត ឬប៉ុនប៉ងនឹងប្រព្រឹត្ត អំពើឃោរឃៅ ដោយកាយក្តី វាចាក្តី ចិត្តក្តី ចំពោះបុគ្គលិកសាលា និងសិស្សដទៃ។

៩. មិនឱ្យពោលពាក្យសម្តីអសុរោះ ភូតកុហក ជេរប្រទេច ខ្សឹបខ្សៀវ វាយតប់ បៀតបៀនខាងផ្លូវភេទ និងសម្តែងកាយវិការអាសគ្រាម ចំពោះបុគ្គលិកសាលា និងសិស្សដទៃ។

១០. មិនឱ្យបញ្ចេញអាកប្បកិរិយារំខានដល់សិស្សក្នុងថ្នាក់ ក្នុងបរិវេណសាលា ឬនៅតាមផ្លូវទៅមកសាលា។

១១. មិនឱ្យប្រព្រឹត្តនូវរាល់សកម្មភាពប្លន់ លួចឆក់ សរសេរគូសវាសលើសៀវភៅ គ្រឿងសង្ហារឹម អគារ ជញ្ជាំង តុ កៅអី ឬចោលសំរាមធ្វើឱ្យខូចសោភ័ណភាព ធ្វើឱ្យខ្ទេចខ្ទី ខូចខាតដល់ទ្រព្យសម្បត្តិសាលា ឬទ្រព្យសម្បត្តិអ្នកដទៃ។

១២. មិនឱ្យឃោសនា ចែកចាយខិតបណ្ណ ឬក្រដាសបោះពុម្ពផ្សាយទាំងឡាយ ដែលមិនទាក់ទងនឹងការសិក្សាក្នុងសាលា។

១៣. មិនឱ្យប្រើទូរសព្ទដៃ កុំព្យូទ័រល្បែង ពាក់កាសត្រចៀក ប្រើវិទ្យុ ម៉ាស៊ីនថតសំឡេង ឬថតរូបនៅក្នុងថ្នាក់រៀន។

១៤. ត្រូវធ្វើតាមការពន្យល់ណែនាំរបស់គ្រូ និងបុគ្គលិករដ្ឋបាល ត្រូវគោរពវិន័យ និងបទបញ្ជាក្នុងថ្នាក់រៀននីមួយៗចៀសវាង ការរំខានដល់សិស្សដទៃ។

១៥. ត្រូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យបន្ទាប់ពីបានឈប់ និងយកមេរៀនត្រឡប់មកសាលាវិញឱ្យទាន់ពេលកំណត់។

១៦. ត្រូវសម្តែងការស្មោះត្រង់ មិនលួចបន្លំតេស្ត កិច្ចការផ្ទះ សំណួរសរសេរ និងក្លែងបន្លំហត្ថលេខា។

១៧. ត្រូវមករៀនឱ្យបានមុន ឬទាន់ពេលរាល់ថ្ងៃ លើកលែងតែមានជម្ងឺ និងបានសុំច្បាប់ត្រឹមត្រូវ។

ថ្ងៃសុក្រ ០៤កើត ខែ ទុតិយសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ២០២៣

**គណៈគ្រប់គ្រងសាលា**